# Tips to Avoid Durable Medical Equipment Fraud

មេឌិឃារ បង់ថ្លៃ ឧបករណ៍ពេទ្យដែលជាប់បានយូរ [(durable medical equipment (DME)], គ្រឿងជំនួសសរីរាង្គ (prosthetics), ប្រដាប់ជួយទប់ទ្រសរីរាង្គ (orthotics) និង សម្ភារៈដាក់លាក់ជាច្រើនប្រភេទ នៅពេលដែល គ្រឿងប្រដាប់ទាំងនេះ **មានភាពចាំបាច់តាមផ្លូវពេទ្យ (medically necessary)**។ នេះមានន័យថា វេជ្ជបណ្ឌិត ចាំបាច់ត្រូវចេញសំបុត្រទិញ ឧបករណ៍នេះ មុនពេល មេឌិឃារ បង់ថ្លៃអោយ។ បើអ្នកត្រូវការ ឧបករណ៍ ឬ សម្ភារៈពេទ្យ ចូរទាក់ទងវេជ្ជបណ្ឌិត របស់អ្នក **ជាមុន**។ កាលណា វេជ្ជបណ្ឌិត របស់អ្នក យល់ព្រម ឱ្យទទួលDME, គ្រឿងជំនួសសរីរាង្គ, ប្រដាប់ជួយទប់ទ្រសរីរាង្គ ឬ សម្ភារៈទាំងឡាយ អ្នកអាចរក អ្នកផ្គត់ផ្គង់សម្ភារៈ DME ដែល បានអនុញ្ញាតដោយ មេឌិឃារ ដោយទូរស័ព្ទទៅ 1-800-MEDICARE ឬ ចូលមើលវ៉ិបសៃ មេឌិឃារ, www.medicare.gov ។ អ្នកផ្គត់ផ្គង់សម្ភារៈ DME គប្បីណាត់ពេលជួប ដើម្បីសាក ឬលមើល ជាមួយអ្នក មុនពេល ផ្តល់អោយអ្នកនូវ ឧបករណ៍ណាមួយ ដើម្បី បញ្ជាក់ថា ឧបករណ៍នោះ សមល្មម និង ដើរត្រឹមត្រូវ សម្រាប់អ្នក និង នៅក្នុងផ្ទះរបស់អ្នក។

**តទៅនេះគឺជា ចំណុចសំខាន់ៗ (tips) ខ្លះៗដើម្បីចៀសវាង**
**នូវការក្លែងបន្លំឧបករណ៍ពេទ្យដែលជាប់បានយូរ**(DME)**:**

## <u>**ចូរកុំ...**</u>

- **ចូរកុំ** អោយលេខ មេឌិឃារ របស់អ្នក ទៅជនណា ដែលអ្នកមិនស្គាល់, ជាពិសេស ជនដែលហៅតាមទូរស័ព្ទ, មកដល់មាត់ទ្វារ, ឬ ផ្តល់ សេវាកម្ម "ឥតគិតថ្លៃ" ដើម្បី ប្តូរ យក លេខ មេឌិឃារ របស់អ្នក នោះឡើយ។ សេវាកម្ម "ឥតគិតថ្លៃ" មិនតម្រូវឱ្យមាន លេខ មេឌិឃារ របស់អ្នកទេ!

- **ចូរកុំ** ទទួលយក ឧបករណ៍ ឬ សម្ភារៈ ពីជនណា ដែលហៅតាមទូរស័ព្ទ ឬ ទៅមើលអ្នក ដោយឥតបានប្រាប់ទុកជាមុន ទោះបីជា គេនិយាយថា វេជ្ជបណ្ឌិត របស់អ្នក បានបញ្ជូនពួកគេមកក៏ដោយ!

- **ចូរកុំ** ទទួលយក ឧបករណ៍ "ឥតគិតថ្លៃ" នៅ កន្លែងបទបង្ហាញ (presentations) ឬ ព្រឹត្តិការណ៍ ណាមួយ ឬ ឧបករណ៍ ដែលមិន ចេញបញ្ជាដោយ គ្រូពេទ្យ (doctor) របស់អ្នក នោះឡើយ។

# Tips to Avoid Durable Medical Equipment Fraud

- **ចូរកុំ** ចុះហត្ថលេខាលើកិច្ចសន្យា ឬលើ ក្រដាសស្នាម (forms) ផ្សេងៗទៀត ដោយមិនបានអាន វា ហើយមិនត្រូវ ចុះហត្ថលេខាលើ ក្រដាសស្នាម ដែលនៅចន្លោះទទេ នោះឡើយ។

**ចូរធ្វើ...**

- **ចូរ** ទាក់ទងគ្រូពេទ្យរបស់អ្នក បើអ្នកគិតថា អ្នកប្រហែលជាត្រូវការ ឧបករណ៍ពេទ្យជាប់បានយូរ, គ្រឿងប្រើជំនួសសរីរាង្គ, ប្រដាប់ជួយទប់ទ្រសរីរាង្គ ឬ សម្ភារៈទាំងឡាយ។ គ្រូពេទ្យរបស់អ្នកគប្បីបញ្ជាទិញ សម្ភារៈទាំងឡាយណា ដែលអ្នកត្រូវការ ។

- **ចូរ** អាន កំណត់ហេតុសង្ខេបមេឌិឃារ _ Medicare Summary Notice (MSN) របស់អ្នក ឬ សេចក្ដីពន្យល់អំពីផលកម្រៃ _ Explanation of Benefits (EOB) ពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក ។ ចូរពិនិត្យមើល ការទាមទារនៃសេវាកម្ម ឬ សម្ភារៈ ដែលអ្នកមិនបានទទួល, សេវាកម្ម ឬ សម្ភារៈ ដែល មិន ត្រូវបានបញ្ជាទិញដោយ គ្រូពេទ្យរបស់អ្នក ឬ កំហុសនៃថ្លៃចំណាយផ្សេងៗទៀត ។

កម្មវិធី SMP (Senior Medicare Patrol – ការត្រួតពិនិត្យមេឌិឃារមនុស្សចាស់) រដ្ឋអ៊ីល្លីណយ អប់រំ អ្នកប្រើប្រាស់ អំពី ការក្លែងបន្លំ, កាកសំណល់ និង ការរំលោភ (abuse) លើការថែទាំសុខភាព។ បើអ្នកមានសំណួរ ស្ដីពី ការទាមទារ លើ កំណត់ហេតុសង្ខេបមេឌិឃារ ឬ សេចក្ដីពន្យល់នៃផលកម្រៃ, ចូរហៅទៅ កម្មវិធី Illinois SMP លេខ **(800)699-9043** ។ ពត៌មានទាក់ទងអំពី កម្មវិធី Illinois SMP គឺអាចរកបាននៅលើ វ៉ែបសៃ របស់យើង **www.illinoissmp.org** ផងដែរ ។

ឯកសារនេះ ត្រូវបានឧបត្ថម្ភឡើង មួយផ្នែក ដោយលេខថវិកា 90MP0026 នៃរដ្ឋបាលសហរដ្ឋ ស្ដីពី មនុស្សចាស់ជរា, ក្រសួងសេវាកម្ម សុខភាព និង ក្រសួងមនុស្សធម៌ ។ អ្នកទទួលប្រាក់ ដែលកំពុងអនុវត្ត កិច្ចការ ក្រោមកិច្ចធានារ៉ាប់រងរបស់រដ្ឋាភិបាល ត្រូវបានលើកទឹកចិត្ត ដើម្បី បញ្ចេញគំហើញ និង សេចក្ដីសន្និដ្ឋាន របស់គេ ដោយសេរី ។ ដូច្នេះ ទស្សនៈយល់ឃើញ ឬ គំនិតយោបល់ ទាំងឡាយ គឺមិនមែន ជាការចាំបាច់ ដើម្បី តំណាងអោយ រដ្ឋបាលផ្លូវការ អំពី គោលនយោបាយមនុស្សចាស់ជរា នោះទេ ។